# យុវជន និង បរិស្ថាន

Youth and Environment

ព្រឹត្តិបត្ររបស់**បណ្តាញសកម្មជនបរិស្ថាន**នៃសមាគមថែរក្សាបរិស្ថាន និងវប្បធម៌

លេខទី ៤ & ៥ ឆ្នាំទី២

ធ្នូ-ឧសភា ឆ្នាំ ២០០៨




**យុវជនជាអនាគតរបស់បរិស្ថានយើង...រួមគ្នាការពារបរិស្ថាន!**



*វិសាលភាពបឹងជើងឯកដែលជាអាងប្រព្រឹត្តកម្មទឹកធម្មជាតិ និងជាប្រភពចំនួលរបស់ប្រជាជន*

អត្ថបទខាងក្នុង ទំព័រ


| អត្ថបទខាងក្នុង | ទំព័រ |
|---|---|
| ១. បរិយាយលេខនេះ យុវជន និងការការពារបរិស្ថាន | ១ |
| ២. បរិយាយលេខនេះ យុវជននិងការគ្រប់គ្រងធនធានជលផល | ៤ |
| ៣.ការចូលរួមរបស់យុវជនក្នុងគំរោងសាលាភូមិ | |
| ៤.ការអភិរក្ស និងការអភិវឌ្ឍន៏ | ៦ |
| ៥. ការបញ្ចាំងខ្សែភាពយន្ត ដល់ពេលត្រូវរកយុត្តិធម៌ នៅខេត្តស្ទឹងត្រែងរបស់ទីន | ៨ |
| ៦. ការសិក្សាពី ជីវភាពរស់នៅរបស់ប្រជាជននៅបឹងជើងឯក | ១០ |
| ៧. ក្រុមបណ្តាញសកម្មជនបរិស្ថានក្នុងការបង្កើតក្រុមយុវជននៅខេត្តស្ទឹងត្រែង | ១២ |
| ៨. ការបំបួសដើមឈើ | |
| ៩. ការបង្កើត និងបំផ្លាញអូសូននៅស្រទាប់ស្ត្រាតូស្វ៊ែរ | ១៤ |
| ១០.ទស្សនៈយុវជន | ១៦ |
| ១១. ពីនេះ-ពីនោះ-ពីបរិស្ថាន | |
| ១២. វេទិកា សំនួរ និង ចំលើយ | ១៨ |
| ១៣. កំណាព្យ | ២០ |
| ១៤ .កំសាន្ត និង សំណើច | ២២ |
| ១៤. កំសាន្ត និង សំនេ | |
| ១៤ជផលវៈ | ២៣ |
| ១៤៤ | ២៤ |
| ១១ | ២៥ |


## បរិយាយលេខនេះ!!



### យុវជន និងការការពារបរិស្ថាន

ជាការពិតណាស់ យុវជនគឺជាទំពាំងស្នងឬស្សី និងជាវ័យមួយដែលពោរពេញទៅដោយកំលាំងប្រាជ្ញា ដែល-មានតួនាទីក្នុងការអភិវឌ្ឍន៍ សង្គមជាតិរួមទាំងបរិស្ថានផងដែរ។ សំនួរសួរថា "**តើយុវជនអាចចូលរួមក្នុងកិច្ចការពារបរិស្ថានដោយរបៀបណា?**" ដូចដែលបានរៀបរាប់នៅលេខមុនខ្លះៗ រួចមកហើយស្តីអំពីឥរិយាបថរបស់យុវជននៅតាមទីសាធារណៈទៅលើបរិស្ថាន ដែលជាចំនុចសំខាន់មិនអាចមើលរំលងបាន។ ការមិចេះអនាម័យត្រ ខាកស្តោះ បន្ទោរបង់ និង ( តទៅទំព័រ ទី៣)




ចេញផ្សាយរៀងរាល់ត្រីមួយខែ

# ព្រឹត្តិប័ត្រ យុវជន និង បរិស្ថាន


**គណៈកម្មការត្រួតពិនិត្យ**

លោក នេព ប៊ុណ្ណារិទ្ធិ

លោកស្រី លុយ រស្មី

លោក គីត ខណ្ណារ៉ា

កញ្ញា ឆាយ គីមហ៊ាត

**ក្រុមអ្នកស្រាវជ្រាវ និពន្ធ និងរៀបរៀង**

កញ្ញា ឆួន រដ្ឋា

កញ្ញា សេង សុរចនា

កញ្ញា គី ណារ៉ាឡែន

កញ្ញា យាង ស៊ាងលី



**អាសយដ្ឋានទំនាក់ទំនងៈ**

ផ្ទះលេខ ៥៩ ផ្លូវលេខ ១៥៦ សង្កាត់ផ្សារដេប៉ូ ១
ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ប្រអប់សំបុត្រប្រៃសណីយ៍: ១៤៨៦
ប្រអប់សំបុត្រ CCC: ៣៥៧
ទូរស័ព្ទ (៨៥៥)២៣ ៣៦៩ ១៧៩
ឬ (៨៥៥)១១ ២៩៥ ០២៣
E-mail: newsye@citylink.com.kh


## បណ្តាញសកម្មជនបរិស្ថាន

## THE ENVIRONMENT ACTIVIST NETWORK (TEAN)

### ១. ប្រវត្តិសង្ខេប

ក្នុងខែឧសភា ឆ្នាំ២០០២ សិក្ខាកាមដែលបានបញ្ចប់វគ្គសិក្សានៅអង្គការសេប៉ាបានចងក្រងគ្នាជាបណ្តាញមួយដែលមានឈ្មោះថា បណ្តាញសកម្មជនបរិស្ថាន ហៅកាត់ថា (TEAN) ក្រោមគំនិតផ្តួចផ្តើមពីអង្គការសេប៉ា ដែលអង្គការនេះប្រាថ្នាចង់បាននូវសង្គមឯករាជ្យមួយដែលថែរក្សាបាននូវវប្បធម៌ និងបរិស្ថានដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដើម្បីធានាឱ្យបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ស្ថិរភាព និងសុវត្ថិភាពសម្រាប់កូនខ្មែរជំនាន់ក្រោយ ។

### ២. គោលដៅ

ធានាឱ្យបាននូវការថែទាំ និងការការពារបរិស្ថាន និងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយសមធម៌ឆ្ពោះទៅរកនិរន្តរភាពនៃការប្រើប្រាស់ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងកូនខ្មែរជំនាន់ក្រោយ ។

### ៣. សកម្មភាព

ដើម្បីសម្រេចបាននូវគោលដៅខាងលើ បណ្តាញសកម្មជនបរិស្ថានបានបង្កើតផ្នែកចំនួនបីដូចខាងក្រោម :

#### ក. ផ្នែកបណ្តុះបណ្តាល និងផ្សព្វផ្សាយសហគមន៍

ផ្នែកនេះត្រូវបានបង្កើតឡើងដើម្បីពង្រឹងចំណេះដឹងដល់សហគមន៍ទាក់ទងនឹងដំណើរការគ្រប់គ្រងសហគមន៍ក៏ដូចជា ចំណេះដឹងទូទៅទាក់ទងនឹងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

#### ខ. ផ្នែកផ្សព្វផ្សាយតាមព្រឹត្តិប័ត្រ

ផ្នែកនេះបង្កើតឡើងដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាជន ពិសេសយុវជនអំពីអត្ថប្រយោជន៍ និងផលប៉ះពាល់នៃបរិស្ថានក្នុងសង្គមខ្មែរ ។

#### គ. ផ្នែកសិក្សាស្រាវជ្រាវពីបញ្ហាបរិស្ថាន

ផ្នែកនេះបង្កើតឡើងដើម្បីចុះសិក្សាក៏ដូចជាស្វែងរកបញ្ហាទាក់ទងនឹងបរិស្ថានដែលកើតមាននៅតាមសហគមន៍មូលដ្ឋាន ដើម្បីជាមធ្យោបាយស្វែងរកដំណោះស្រាយ ។




កាកសំនល់ជាដើម គឺសុទ្ធសឹងជាការសំដែងសកម្មភាពដែលបំផ្លាញទាំងសោភ័ណភាពសាធារណៈ និងបរិស្ថាន ដូចនេះយុវជនគួរតែជៀសវាង។

ការប្រកាន់យកឥរិយាបថល្អ មានវិន័យសណ្តាប់ធ្នាប់មិនថាក្នុងគេហដ្ឋាន សហគមន៏ ក៏ដូចជាទីសាធារណៈ គឺមានន័យថាយុវជនបានចូលរួមក្នុងការលើកកំពស់ និងគិតគូរដល់បរិស្ថានរួចទៅហើយ។ លើសពីនេះទៅទៀត យុវជនអាចចូលរួមការពារបរិស្ថានតាមរយៈការបង្កើតជាក្រុមយុវជន ដើម្បីចូលរួមក្នុងសកម្មភាពនានាដូចជា ការចុះផ្សព្វផ្សាយតាមសហគមន៏ការចូលរួមដើរក្បួនយុទ្ធនាការ ការតស៊ូមតិជាដើម។ តាមរយៈសកម្មភាពទាំងនេះ គឺបានជួយបណ្តុះគំនិតយុវជនអោយកាន់តែយកចិត្តទុកដាក់ដល់បរិស្ថាន និងអាចជួយធ្វើអោយសាធារណៈជនទូទៅ ក៏ដូចជាយុវជនជំនាន់ក្រោយយកគំរូតាមផងដែរ។ ម្យ៉ាងទៀត ការធ្វើការងារជាក្រុម អាចធ្វើអោយយុវជនស្គាល់គ្នាកាន់តែច្បាស់ ចេះចែករំលែកគំនិតយោបល់ បទពិសោធន៏ព័តិមាន ក៏ដូចជាជួយគ្នាស្វែងរកដំណោះស្រាយឆ្លើយតបនឹងបញ្ហាបរិស្ថានដែលកំពុងជួបប្រទះបានយ៉ាងល្អប្រសើរ។ ពួកគេមិនត្រឹមតែបានជួយដល់សង្គមក្នុងការថែរក្សាបរិស្ថានដោយផ្ទាល់ប៉ុណ្ណោះទេ គឺថែមទាំងបានជួយផ្សព្វផ្សាយ និងណែនាំដល់ក្រុមគ្រួសារ មិត្តភ័ក្រ្ត អ្នកជិតខាង និងសហគមន៏របស់គេអោយយល់ដឹងពីបរិស្ថាន ហើយចូលរួមក្នុងការថែរក្សា ការពារទាំងអស់គ្នាទៀតផង។ ជាងនេះទៅទៀតចំពោះយុវជនដែលកំពុងសិក្សារៀនសូត្រ ក៏អាចចូលរួមថែរក្សាបរិស្ថានបានផងដែរ តាមរយៈការបង្កើនចំនេះដឹងអំពីបរិស្ថានទាក់ទងនឹងផលប៉ះពាល់ ផលប្រយោជន៏ និងការស្វែងយល់នូវដំណោះស្រាយបញ្ហាបរិស្ថាន ដែលចំនេះដឹងនិងពតិមានទាំងនោះគឺជាបច្ច័យដ៏មានប្រយោជន៏សំរាប់ពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។ តួយ៉ាង នៅពេលដែលគេក្លាយទៅជាអ្នកបន្តវេនដឹកនាំប្រទេស ពួកគេនឹងយកចិត្តទុកដាក់គិតដល់បញ្ហាបរិស្ថាន មុននឹងសំរេចធ្វើគំរោងអភិវឌ្ឍន៏ណាមួយ។



*ក្បួនដង្ហែអបអរសាទរទិវាបរិស្ថានរបស់យុវជន ដែលធ្វើនៅខេត្តសៀមរាប*

ជារួមមក ការចូលរួមរបស់យុវជនពិតជាមានអត្ថប្រយោជន៏យ៉ាងប្រត្យក្ស ក្នុងការលើកកំពស់បរិស្ថានអោយមានលំនឹង និងស្រស់បំព្រង។ ការយល់ដឹងអំពីបរិស្ថាននាំអោយយុវជនប្រកាន់ឥរិយាបថល្អដែលមិនធ្វើអោយបរិស្ថានទទួលផលប៉ះពាល់ និងការគំរាមគំហែង ហើយជាពិសេសការចូលរួមពីពួកគេតាមការស្ម័គ្រចិត្តចងក្រងជាក្រុម ក៏ដូចជាសកម្មភាពក៏អាចជួយដល់ការថែរក្សាបរិស្ថានអោយមានដំណើរការប្រសើរដែរ។ គ្រប់សម្មភាពរបស់យុវជនដូចដែលបានរៀបរាប់ខាងលើនេះ គឺនឹងជួយអោយបរិស្ថានមាន-ភាពស្រស់ត្រកាល និងសង្គមមានសណ្តាប់ធ្នាប់ល្អ។ " ***សូមយុវជនខ្មែរទាំងឡាយចេះចូលរួមថែរក្សា ការ-ពារបរិស្ថាន កុំអោយ ទទួលរងនូវការបំផ្លិចបំផ្លាញ ព្រោះបរិស្ថានជាជីវិត*** "។

***ដោយកញ្ញា យាង ស៊ាងលី សកម្មជនបរិស្ថាន ជំនាន់ទី១៨***

បរិយាយលេខនេះ!!

# យុវជន និងការគ្រប់គ្រងធនធានជលផល

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងអភិវឌ្ឍខ្លួនទៅរកភាពរីកចំរើនលើគ្រប់វិស័យ ដូចជា វិស័យព្រៃឈើ កសិកម្ម ទេសចរណ៍ និងឧស្សាហកម្មជាដើម។ ដោយឡែក វិស័យជលផលក៏ជាវិស័យមួយត្រូវ ដែលបានគេយកចិត្តទុកដាក់ និងចាត់ទុកជាវិស័យអាទិភាពមួយដែរ ពីព្រោះប្រជាជនភាគច្រើននៅក្នុងប្រទេសនេះជាកសិករប្រកប របរកសិកម្ម និងនេសាទដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃ។ តាំងពីដើមរៀងមក គេសង្កេតឃើញថា ភាគច្រើនមាន តែមនុស្សដែលមានបទពិសោធច្រើន និងចំនេះដឹងទេ ដែលអាចចូលរួមក្នុងការគ្រប់គ្រងធនធានទាំងនេះ ប៉ុន្តែសព្វថ្ងៃ វត្តមានរបស់យុវជនក៏ត្រូវបានរាប់បញ្ចូល និងដើរតួនាទីជាអ្នកចូលរួមត្រួតពិនិត្យ ការប្រើប្រាស់ ការការពារថែរក្សា ការបញ្ចេញយោបល់ដើម្បីឱ្យមាននិរន្តរភាពលើការប្រើប្រាស់។ យុវជនទាំងនោះអាច ជាអ្នកប្រើប្រាស់បន្ត ជាធនធានមនុស្សទៅថ្ងៃអនាគតលើការគ្រប់គ្រងបន្តពីមនុស្សពីជំនាន់មុន ជាអ្នកផ្សព្វផ្សាយបន្តនិងធានាលើការអនុវត្តផែនការការពារ និងគ្រប់គ្រងយូរអង្វែង។ ទន្ទឹមគ្នានេះដែរ អង្គការពាក់ព័ន្ធនឹងយុវជនជាច្រើនបានបង្កើតនូវយុទ្ធនាការក៏ដូចជាយុទ្ធសាស្ត្រជាច្រើនក្នុងការលើកទឹកចិត្ត និង បង្កើនសំលេងរបស់យុវជនពីព្រោះថាពួកគេនឹងក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិនាពេលខាងមុខ។ ការចូលរួមរបស់យុវជនក្នុងដំនើរការ ឬផែនការអភិវឌ្ឍន៍ណាមួយ គឺអាចឱ្យពួកគេបានរៀនសូត្រពីមនុស្សចាស់ ក៏ដូច ជាទទួលបានបទពិសោធព្រមទាំងអាចចែករំលែកចំនេះដឹង និង ព័ត៌មានទាំងនោះទៅយុវជនគ្នាឯង ដែល ជាយាន្តឱ្យពួកគេកាន់តែយល់ដឹងពីតួនាទី និងកាតព្វកិច្ចក្នុងការជួយស្តារ និង អភិវឌ្ឍប្រទេសជាតិ។

តាមរយៈ គំរោងមួយឈ្មោះ *សាលាភូមិ* ទាក់ទងនឹងធនធានត្រី និងជីវភាពរបស់ប្រជាជននៅតាមដងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែងបានបង្ហាញថា ការចូលរួមរបស់យុវជនក្នុងការត្រួតពិនិត្យ និងអនុវត្តជាក់ស្តែងព្រមទាំងការបញ្ចេញមតិយោបល់ក្នុងការតាមដានទីជំរកត្រីជាមួយមនុស្សចាស់ក្នុងភូមិខ្លួន។ ផ្អែកលើគំរោងនេះដែរ ពួកគេមិនត្រឹមតែបានទទួលនូវចំនេះដឹងថ្មីៗ និងបទពិសោធដែលបានចែករំលែកពីមនុស្សចាស់នោះទេ ពួកគេថែមទាំងបញ្ចេញមតិតាមរយៈការធ្វើបទបង្ហាញផ្សេងៗនៅក្នុងអង្គប្រជុំវិសិក្ខាសាលាផងដែរ។ ស្របពេលជាមួយគ្នានេះដែរ គេក៏បានសង្កេតឃើញពីកត្តារារាំងមួយចំនួនដែលធ្វើឱ្យយុវជនមានការពិបាកក្នុងការចូលរួមដោយ សារមូលហេតុចំបងគឺកត្តាជីវភាពដែលតំរូវឱ្យពួកគេធ្វើចំនាកស្រុក រឺត្រូវទៅធ្វើការយកកំរៃ ជាពិសេសគឺត្រូវនៅជួយការងាររបស់ឪពុកម្តាយរបស់គេ។ ឧបសគ្គទាំងនេះ គឺបានធ្វើឱ្យពួកគេមិនអាចចូល រួមដែលជាមូលហេតុធ្វើឱ្យពួកគេមិនមានចំនេះដឹង ដូចនេះ ពួកគេងាយនឹង ប្រព្រឹត្តកំហុស ឆ្គងផ្សេងៗ ដែលផ្តល់ផលវិបាកដល់សហគមន៍ និងសង្គមជាតិទៅវិញ។ ដើម្បីជៀសវាងបញ្ហាទាំងនេះកើតឡើងបានការ ចូលរួមរបស់យុវជនគួរតែត្រូវបានផ្សព្វផ្សាយ **និងទទួលស្គាល់**លើគ្រប់វិស័យដើម្បីឱ្យពួកគេបានចូលរួមចំណែក កសាងសង្គមជាតិមួយប្រកបដោយប្រសិទ្ធិភាព។

ជាទីបញ្ចប់ វត្តមានរបស់យុវជនទាំងឡាយក្នុងការគ្រប់គ្រងធនធានជលផលក៏ដូចជាធនធានផ្សេងៗ គឺពិតជាមានអត្ថប្រយោជន៍ណាស់ក្នុងការលើកកំពស់វិស័យទាំងនោះឱ្យមានភាពរីកចំរើនជាមួយការប្រើប្រាស់ដោយចីរភាព។ មូលហេតុចំបងៗជាច្រើនដែលគេគួរបញ្ចូលយុវជនទៅក្នុងការវិស័យជលផលមានជាអាទិ៍ យុវជនជាអ្នកទៅប្រមូលធនធានដោយផ្ទាល់នោះពួកគេដឹងពីស្ថានភាពជាក់ស្តែងយុវជនជាអ្នកប្រឈមមុខដោយផ្ទាល់ជាមួយបញ្ហាបាត់បង់ធនធានត្រី យុវជនក៏ជាអ្នកដែលរួមចំនែកប្រព្រឹត្តបទល្មើសនេសាទគួរឱ្យកត់សំគាល់ដែរ ។យុវជនមានការចូលរួម នាំឱ្យពួកគេអាចទទួលបានចំនេះដឹង បទពិសោធ ដូចនេះសកម្មភាពមិនសមស្រប ឬខុសច្បាប់នឹងត្រូវបានកាត់បន្ថយ ឬលុបបំបាត់ ព្រោះពួកគេជាអ្នកអនុវត្ត និងប្រើប្រាស់ធនធាននៅថ្ងៃមុខ។ មានន័យថា នៅពេលពួកគេមានការយល់ដឹង នោះពួកគេនឹងមិនធ្វើឱ្យមានបញ្ហាឡើយ ។ ទៅថ្ងៃអនាគតដ៏ខ្លី ខាងមុខនេះគេសង្ឃឹមថាការចូលរួម និងសំលេងរបស់យុវជននឹងក្លាយជាសារមួយដ៏ល្អនឹងមានប្រយោជន៍ដែលនឹងត្រូវយកទៅប្រើប្រាស់ក្នុងការអនុវត្តលើផែនការអភិវឌ្ឍនានាក្នុងការកសាងប្រទេសជាតិឆ្ពោះទៅរកភាពរីកចំរើននិងមោទនភាព។ ***" យុវជនទាំងឡាយអើយ អ្នកនេះហើយគឺជាធនធានដ៏មានតំលៃដែលមិនអាចកាត់ថ្លៃ បានក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងអភិវឌ្ឍជាតិទៅថ្ងៃអនាគត។"***

***ដោយកញ្ញា ឃាង ស៊ាងលី សកម្មជនបរិស្ថាន ជំនាន់ទី១៨***

# ការចូលរួមរបស់យុវជន ក្នុងគំរោងសាលាភូមិ

គំរោងសាសាភូមិជាគំរោងស្រាវជ្រាវនៅតំបន់វាំសារ ខេត្តស្ទឹងត្រែងដែលបានទទួលការគាំទ្រ និងសហប្រតិបត្តិការរវាងអង្គការក្នុងស្រុកមួយដែលមានឈ្មោះថា សមាគមន៏ថែរក្សាបរិស្ថាន និងវប្បធម៌ CEPA និងអង្គការ IUCN ក្រោមកម្មវិធីអភិរក្សជីវៈចំរុះតំបន់ដីសើមទន្លេមេគង្គ MWBP ។ គំរោងនេះអនុវត្តចាប់តាំងពីខែឧសភា ឆ្នាំ២០០៥មក នៅភូមិចំនួន៤ តាមដងទន្លេមេគង្គមានភូមិកោះល្វ ភូមិរឿនសៀន ភូមិកោះស្នែង និងភូមិកោះខនឌិន ដោយមានប្រជាជន ៩៤នាក់ចូលរួមក្នុងការស្រាវជ្រាវ និងប្រមូលទិន្នន័យលើប្រធានបទៈ

- ធនធានជលផល(រួមមានប្រភេទត្រី ឧបករណ៏នេសាទបែបបុរាណ កន្លែងរស់នៅរបស់ត្រី និងការបំលាស់ទីរបស់ត្រី
- ប្រភេទរុក្ខជាតិប្រើប្រាស់ជាបន្លែ និងឱសថ និង
- ប្រភេទជំរកសំខាន់ៗរបស់ត្រី

**គំរោងស្រាវជ្រាវសាលាភូមិ មានគោលបំណងសំខាន់ៗចំនួន៤ះ**

- ដើម្បីលើកកំពស់សិទ្ធិអំណាចដល់ប្រជាជនមូលដ្ឋាន និងបង្កើនចំណេះដឹងដល់ពួកគេពីធនធានធម្មជាតិដែលមាននៅក្នុងភូមិរបស់ពួកគេតាមរយៈការសិក្សាស្រាវជ្រាវដោយខ្លួនឯង
- ដើម្បីបរិយាយ និងត្រួតពិនិត្យមើលការប្រែប្រួលនៃធនធានធម្មជាតិ
- បណ្តុះបណ្តាលក្រុមអ្នកស្រាវជ្រាវ អោយចេះពីរៀបធ្វើការជាបណ្តាញ ដើម្បីផ្លាស់ប្តូរចំណេះដឹងរវាងគ្នា និងគ្នាក្នុងរង្វង់ភូមិរបស់ខ្លួន
- ដើម្បីប្រមូល និងចងក្រងឯកសារពីចំណេះដឹងតាមមូលដ្ឋានដែលទាក់ទងនឹងធនធានធម្មជាតិនៅក្នុងភូមិរបស់ពួកគេ

តាមរយៈ លោកអ៊ុយ សុភាវីរៈ អ្នកសម្របសម្រួលគំរោងបានបញ្ជាក់អោយដឹងថា ក្នុងចំនោមប្រជាជន៩៤នាក់ ដែលចូលរួមក្នុងគំរោងនេះ មានយុវជនប្រហែល ៤0% ។ ពីដំបូងឡើយ គឺយុវជនទាំងនោះមានឆន្ទៈក្នុងការចូលរួមក្នុងគំរោងនេះដោយខ្លួនឯង ដោយហេតុតែពួកគេយល់ឃើញថាវាជាការងារដែលមានប្រយោជន៏សំរាប់ភូមិរបស់គេ និងជាពិសេសគឺមានការជំរុញពីឪពុកម្តាយដែលពួកគាត់គិតថាគំរោងនេះនឹងផ្តល់ចំណេះដឹងបន្ថែមដល់កូនរបស់គាត់ និងចង់អោយកូនគាត់ចូលរួមក្នុងការថែរក្សាធនធានធម្មជាតិដែលជាប្រយោជន៏ប្រើប្រាស់សំរាប់ពួកគេទៅថ្ងៃអនាគត។ ថ្វីត្បិតតែ យុវជនទាំងនោះនៅវ័យក្មេង ប៉ុន្តែចំណេះដឹងរបស់ពួកគេទាក់ទងនឹងការនេសាទ និងធនធានធម្មជាតិនៅក្នុងភូមិនចាញ់ចាស់ៗជំនាន់មុនប៉ុន្មានឡើយ ទោះជាបទពិសោធន៏របស់ពួកគេមិនទាន់ស្ទាត់ជំនាញដូចមនុស្សចាស់ក៏ដោយ។

យុវជនពិតជាមានឆន្ទៈនឹងចូលរួមក្នុងគំរោងនេះដោយទឹកចិត្តពិតប្រាកដ ជាក់ស្តែងពួកគេបានចូលរួមផ្លាស់ប្តូរយោបល់ និងធ្វើការងារជាក្រុមនៅពេលចែកក្រុមពិភាក្សា ការចូលរួមកត់របាយការណ៍ និងចូលរួមក្នុងការប្រជុំ និងសិក្ខាសាលានានា។ មិនត្រឹមតែចំណាយពេលវេលា និងទឹកចិត្តក្នុងការចូលរួមតាមដានធនធាននៅក្នុងភូមិប៉ុណ្ណោះទេ យុវជនថែមទាំងចំណាយថវិកាផ្ទាល់ខ្លួនក្នុងសកម្មភាពផ្សេងៗទៀត ដូចជា ចំណាយប្រាក់ចាក់សាំងទូក និងពេលខ្លះដឹងអ្នកធ្វើការក្នុងគំរោងទៅបំពេញបេសកកម្មដោយ មិនគិតថ្លៃឈ្នួល។

លោកអ៊ុយ សុភាវីរៈ បានទទួលស្គាល់ថាការចូលរួមរបស់យុវជនពិតជាមានសារៈសំខាន់នៅក្នុងគំរោងនេះ ដោយសារយុវជនជាមនុស្សពេញកំលាំង ហើយនៅតាមគ្រួសារនីមួយៗភាគច្រើនគឺយុវជនជាអ្នកចេញទៅនេសាទច្រើនជាងមនុស្សចាស់ដែលមិនសូវមានកំលាំង។ ដូច្នេះ បើយុវជនបានចូលរួមនៅក្នុងគំរោងនេះពួកគេនឹងបានយល់ច្បាស់ពីសារៈប្រយោជន៍នៃធនធានធម្មជាតិ និងច្បាប់ជលផល នាំអោយពួកគេអាចនឹងកាត់បន្ថយ រឺឈប់ប្រព្រឹត្តិអំពើណាដែលអាចបង្កផលប៉ះពាល់ដល់ធនធាន។ លើសពីនេះទៅទៀតពេលយុវជនចូលរួមក្នុងគំរោងនេះ គេនឹងអាចនៅធ្វើការបន្តបានយូរអង្វែងទៅមុខ និងអាចផ្សព្វផ្សាយដល់ក្មេងៗជំនាន់ក្រោយផង។ ដោយមើលឃើញពីសារៈសំខាន់នៃការចូលរួមរបស់យុវជនដូច្នេះហើយទើបនៅក្នុងគំរោងនេះគេមានការជំរុញ និងទឹកចិត្តអោយយុវជនចូលរួម តាមរយៈការផ្តល់អាទិភាពអោយចូលរួមក្នុងពិធីសង្គមដូចជាសិក្ខាសាលាថ្នាក់ភូមិ ខេត្តអោយពួកគេមានឱកាសទទួលយកបទពិសោធន៍ និងចំណេះដឹងថ្មីៗ ។

***ដោយកញ្ញា ធួន វឌ្ឍា សកម្មជនបរិស្ថានជំនាន់ ១៩***

# ការអភិវឌ្ឍ និងការអភិរក្ស

ការអភិរក្ស មិនមែនជាសកម្មភាពប្រឆាំង នឹងការអភិវឌ្ឍន៏ទេ។ វាជាការទាមទារឱ្យមានការថ្លឹងថ្លែងរវាងផលប៉ះពាល់ និងផលចំនេញ។ ប្រសិនបើចាំបាច់ត្រូវតែមានការអភិវឌ្ឍតែការអភិវឌ្ឍន៏នោះគួរមានការសិក្សា វាយតំលៃលើហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់ មានការពិគ្រោ-ះយោបល់ជាមួយអ្នក ពាក់ព័ន្ធជាពិសេសអ្នកដែលនឹងទទួលរងផលប៉ះពាល់ ពីគំរោង អភិវឌ្ឍន៏និងត្រូវតែ មានវិធីសាស្រ្តកាត់បន្ថយ ឬបញ្ចៀសផល ប៉ះពាល់ទាំងទៅលើបរិស្ថាននិងសង្គម។

**ប្រសិនបើអ្នកដឹងថា មានមាសមួយតោននៅក្រោមឈើ ១000ដើម តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច?**

ថ្មីៗនេះ កម្ពុជាបានទាក់ទាញការវិនិយោគបរទេសច្រើនឡើងៗ ដែលភាគច្រើននៃការវិនិយោគនោះទាក់ទងទៅនឹងធនធានធម្មជាតិដូចជាការលុបបឹងដើម្បីអភិវឌ្ឍក្រុង ការសាងសង់ទំនប់វារីអគ្គិសនី ការអភិវឌ្ឍន៏កោះជារម្យណីដ្ឋានទេសចរណ៏ ការសាងសង់កំពង់ផែការបង្កាត់ពូជស្វាសំរាប់នាំចេញ និង ការ-រុករកធន ធានរ៉ែ ជាដើម។ ការវិនិយោគក្នុងទំហំទឹកប្រាក់រាប់លានដូល្លាត្រូវ បានអនុញ្ញាតិក្នុងគោលបំណងពន្លឿនការ អភិវឌ្ឍន៏ ក្នុងវិស័យសេដ្ឋកិច្ច។ ជាមួយនឹងការអភិវឌ្ឍន៏ផ្នែកវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណា លើការអភិរក្សធនធានធម្មជាតិ និងប្រជាជនដែលនឹងទទួលរងផលប៉ះពាល់ គំរោងអ-ភិវឌ្ឍន៏ទាំងអស់នោះមុន នឹងអនុញ្ញាតឬចេញអាជ្ញាប័ណ្ណដល់ក្រុមហ៊ុនវិនិយោគណាមួយ។

ការវិនិយោគទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធនឹងការប៉ះពាល់ដល់ធនធានធម្មជាតិ និងការបញ្ចេញសំណល់បំពុលទៅក្នុងបរិស្ថានតំរូវឱ្យមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានដោយមានបញ្ចូលការពិគ្រោះយោបល់ជាមួយសាធារណៈជនដែលជាប់ពាក់ព័ន្ធនៅក្នុងគំរោងវិនិយោគនោះ ទើបអាចធ្វើការសំរេចចិត្តលើផែនការវិនិយោគនោះ ។ របាយការណ៏ដែលបានសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានគួរមានការដាក់បង្ហាញជាសាធារណៈដើម្បីរក្សាបាននូវទំនុកចិត្ត និងភាពច្បាស់លាស់។ ប៉ុន្តែ បច្ចុប្បន្នការសិក្សាហេតុប៉ះពាល់របស់គំរោងវិនិយោគភាគច្រើនពុំទាន់ធ្វើបានពេញលេញឡើយ ហើយពុំបានធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា និងអ្នកទទួលរងផលប៉ះពាល់ ហើយម្យ៉ាងទៀតរបាយការណ៏វាយតំលៃផលប៉ះពាល់បរិស្ថានជារឿយៗត្រូវបានរក្សាទុកជាសម្ងាត់ផងដែរ។

**ប្រសិនបើការវិនិយោគលើធនធានធម្មជាតិចេះតែបន្តដោយពុំមានការពិចារណាលើផលប៉ះពាល់ ដល់បរិស្ថានទេនោះ តើបរិស្ថាននឹងក្លាយជាយ៉ាងណា?**

តាមរាយការណ៏ស្រាវជ្រាវរបស់បណ្តាប្រទេសដែលធ្លាប់ទទួលរងផលប៉ះពាល់ពីសកម្មភាពជីករ៉ែខ្នាតតូចបបានបង្ហាញពីផលប៉ះពាល់ដល់បរិស្ថាន និងសង្គមពីការគំរោជីករ៉ែថាការជីករុករករ៉ែគឺជាសកម្មភាពរយៈពេលខ្លី ជាមួយនឹងផលប៉ះ ពាល់រយៈពេលវែង។ ផលប៉ះពាល់ទាំងនោះប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលទៅលើបរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋ ដូចជាការកាប់ព្រៃឈើនៅ តំបន់រុករករ៉ែធ្វើឱ្យមានការការបាត់បង់ប្រភេទរុក្ខជាតិ បាត់បង់ទីជំរកសត្វព្រៃ ការហូរច្រោះដី ការកើតឡើងនៃកំណរនិងប៉ះពាល់ដោយការចូលរកអនុផលព្រៃឈើរបស់ប្រជាជនក្នុងតំបន់។ លោហៈក្រោមដី

និងកង្វក់ទឹកនៅពេលដែលសារធាតុ ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងទឹក។ សារពាង្គកាយនានាដែលរស់នៅក្នុងទឹកទទួលរងផលប៉ះពាល់ពី ទឹកពុលនេះបន្តទៀត ជាពិសេស ធនធានត្រី។ លើសពីនេះទៀតវាកាន់តែបង្កផលប៉ះពាល់ដល់សុខភាព មនុស្សដែលប្រើប្រាស់ទឹកនោះ។

ផលប៉ះពាល់ទៅលើបរិស្ថានមិនមែនជាការប៉ះពាល់តែទៅលើកត្តាមួយនោះទេ វាបន្តបង្កផលប៉ះពាល់ដល់កត្តាផ្សេងៗទៀតតាមរយៈទំនាក់ទំនងធម្មជាតិ (ប្រព័ន្ធអេកូឡូស៊ី) និងបន្តប៉ះពាល់ដល់ការរស់នៅរបស់មនុស្ស ដូចនេះ ប្រសិនបើភាពចាំបាច់ក្នុងការអភិវឌ្ឍន៍លើធនធាន ធម្មជាតិគួរពិចារណា រកវិធីកាត់បន្ថយ រឺទប់ ស្កាត់ផលប៉ះពាល់លើបរិស្ថាន និងសង្គម។

***ដោយ លោក វ៉ាន់ រិទ្ធី សកម្មជនបរិស្ថានជំនាន់ ១៩***

## ការបញ្ចាំងខ្សែភាពយន្តស្តីពី "ដល់ពេលរកយុត្តិធម៌" នៅខេត្តស្ទឹងត្រែង

ខ្សែភាពយន្តភាគខ្លីស្តីពី **"ដល់ពេលរកយុត្តិធម៌"** ត្រូវបានផលិតឡើងដោយក្រុមហ៊ុនខ្មែរមេគង្គដែលជាគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌល East West Center (សហរដ្ឋអាមេរិច) និងមជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាម ក្រោមការឧបត្ថម្ភថវិកាពីស្ថានទូតអង់គ្លេស។ ខ្សែភាពយន្តភាគខ្លីនេះមានចំនួនពីរវគ្គ ដែលវគ្គទីមួយចង់រំលឹកពីជីវិតរស់នៅរបស់ប្រជាជនខ្មែរកាលពីសម័យប៉ុលពត ដោយបង្ហាញពីគ្រួសារមួយដែលឪពុកម្តាយបាននិយាយប្រាប់ទៅកូននូវទុក្ខវេទនារបស់ពួកគាត់កាលពីសម័យនោះ និងវគ្គទីពីរបង្ហាញអំពីដំណើរការក្នុងសាលាក្តីកាត់ទោសខ្មែរក្រហម។

*.ប្រជាជនក្នុងខេត្តស្ទឹងត្រែងមានការចាប់អារម្មណ៏យ៉ាងខ្លាំងចំពោះខ្សែភាពយន្តទាំងពីរវគ្គដែលបញ្ចាំង។ ខ្សែភាពយន្តវគ្គទីមួយបានធ្វើឱ្យពួកគាត់ស្រក់ទឹកភ្នែកដោយការនឹកឃើញពីជីវិតរស់នៅកាលក្នុងរបបខ្មែរក្រហម។ ប៉ុន្តែ ក្រោយពីបានទស្សនាខ្សែភាពយន្តវគ្គទីពីស្តីអំពីដំណើរការសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រជាជនជាអ្នកទស្សនាបែរជាមានទឹកមុខស្រស់ញញឹម និងអង្គុយតាមដានទស្សនាយ៉ាងយកចិត្តទុកដាក់។*

ខ្សែភាពយន្តនេះផលិតឡើងក្នុងគោលបំណងដើម្បីពង្រឹងការផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋានអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាកា កម្ពុជា និងអំពីដំណើរការរបស់សាលាក្តី។ មជ្ឈមណ្ឌល អភិវឌ្ឍន៏សង្គម (CSD) ជាអ្នកសម្របសម្រួលផ្សព្វផ្សាយខ្សែភាពយន្តនេះនៅទូទាំងប្រទេសកម្ពុជា ដោយសហការជាមួយស្ថាប័នសង្គមស៊ីវិលផ្សេងៗទៀត។ អង្គការសេប៉ាបានធ្វើការសហការជាមួយនឹងមជ្ឈមណ្ឌល អភិវឌ្ឍន៏សង្គម (CSD) ដើម្បីធ្វើការបញ្ចាំងខ្សែភាពយន្តនេះនៅក្នុងតំបន់គោលដៅរបស់ខ្លួនក្នុងខេត្តស្ទឹងត្រែង ចំនួន ៣៤ភូមិ ដែល ១០ភូមិស្ថិតតាមដងទន្លេមេគង្គ ១០ភូមិស្ថិតតាមដងទន្លេសេកុង ១២ភូមិស្ថិតតាមដងទន្លេសេសាន និង២ភូមិទៀតស្ថិតនៅតាមដងទន្លេស្រែពក។



ជាលទ្ធផលក្រោយពីការបញ្ចាំង ប្រជាជនក្នុងខេត្តស្ទឹងត្រែងមានការចាប់អារម្មណ៏យ៉ាងខ្លាំងចំពោះខ្សែភាពយន្តទាំងពីរវគ្គនេះពី ព្រោះទាំងការសំដែង និងសាច់រឿង បានធ្វើឱ្យពួកគាត់មិនស្រក់ទឹក ភ្នែកមិនបានជាពិសេសចំពោះរឿងក្នុងវគ្គទីមួយ។ លោកពូម្នាក់នៅភូមិនោះ បានពោលនូវពាក្យមួយឃ្លាទាំង អារម្មណ៏ក្តុកក្តួល និងឈឺចាប់ថា **"តើហេតុអ្វី បានជាយករឿងឈឺចាប់ទាំង នេះមកចាក់បង្ហាញអញ្ចឹង! វាហាក់ដូចជានៅថ្មីៗ ហើយវាជារឿងធ្វើឱ្យយើងឈឺចាប់ ខ្ញុំមិនចង់ដឹងឮតទៅទៀតទេ"**។ ចំណែកប្រជាជនផ្សេងៗទៀតនៅភូមិដទៃទៀត ក៏មានការចាប់អារម្មណ៏ស្រដៀងៗគ្នាបែបនេះដែរ ដោយពួកគាត់ភាគច្រើនក្រៀមក្រំនៅពេលដែល





សកម្មភាពបញ្ចាំងខ្សែភាពយន្តរបស់បណ្ដាញសកម្មជនបរិស្ថានដល់អ្នកភូមិ

គាត់លើកឡើងនូវរឿងឈឺចាប់ ដែលខ្លួនជួបប្រទះនៅសម័យនោះ ។

ដោយឡែក ក្រោយពីបានទស្សនាខ្សែភាពយន្តវគ្គទីពីរស្តីអំពីដំណើរការសាលាកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រជាជនជាអ្នកទស្សនាបែរជាមានទឹកមុខស្រស់ញញឹម និងអង្គុយតាមដានទស្សនាយ៉ាងយកចិត្តទុកដាក់ ។ ពួកគាត់និយាយថា ពួកគាត់មានការសប្បាយចិត្តណាស់ ដោយដឹងថាមានតុលាការកាត់ទោសខ្មែរក្រហម ជាពិសេសដោយមានការចូលរួមពីជនបរទេស ។ គាត់ជឿថា ការកាត់ទោសនាពេលខាងមុខនេះ នឹងមានយុត្តិធម៌ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយពួកគាត់ក៏មានការព្រួយបារម្ភផងដែរ ទាក់ទងនឹងរយៈពេលនៃការកាត់ទោស ដោយបច្ចុប្បន្ននេះ មេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ ភាគច្រើនមានវ័យចាស់ជរាណាស់ទៅហើយ ។ ចំពោះយុវជនវិញក៏មានការជឿជាក់ថាមានការសំលាប់មនុស្សរាប់លាននាក់ពិតប្រាកដមែន ពីសំណាក់ខ្មែរក្រហម នៅក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ការដឹង និងជឿជាក់ថាមាននេះ គឺតាមរយៈឪពុកម្ដាយរបស់ពួកគេនិងដោយសាធ្លាប់រៀនសូត្រនៅតាមសាលារៀន ។ ក្រោយពីទស្សនាខ្សែភាពយន្តទាំងពីរវគ្គរួចមក អ្នកទស្សនាទាំងអស់សំណូមពរសុំឱ្យមានការបន្តបញ្ចាំងខ្សែភាពយន្ត ដែលទាក់ទងនឹងការកាត់ទោសខ្មែរក្រហមនេះទៀត ហើយម្យ៉ាងទៀត ពួកគេស្នើសុំឱ្យមានការ បង្ហាញជាលក្ខណៈឯកសាទាក់ទងនឹងសកម្មភាព ការធ្វើទារុណកម្ម និងពិសេសរូបពិតប្រាកដរបស់មេដឹកនាំ **ខ្មែរក្រហម** ។

ទាក់ទងនឹងការបញ្ចាំងខ្សែភាពយន្តនេះ កញ្ញា ភួង កេសនី ជាបណ្ដាញសកម្មជនបរិស្ថាន ដែលបានដើរតួជាអ្នកសំរបសំរួលផ្ទាល់នៅក្នុងការបញ្ចាំងបានសំដែងនូវការយល់ឃើញយ៉ាងដូច្នេះថា ការបញ្ចាំងខ្សែភាពយន្តនេះជាការល្អប្រសើរណាស់ ប៉ុន្តែនៅតែមានការខ្វះខាតនៅឡើយ។ តាមការសង្កេតរបស់ខ្ញុំ ប្រជាជនភាគច្រើនមិនសូវយល់ពីពាក្យមួយចំនួនដែលប្រើនៅក្នុងខ្សែភាពយន្តទីពីរទេ ដោយសារតែការប្រើពាក្យពេចន៍ទាំងនោះពិបាកយល់ពេក (ពាក្យប្រើនៅក្នុងសាលាក្ដី) ទើបពេលខ្លះធ្វើអោយគាត់មានអារម្មណ៍ធុញថប់។ ទោះជាយ៉ាងនេះក្ដី ក៏ពួកគាត់នៅតែមានចិត្តសប្បាយរីករាយដោយបានដឹងថាមានការទោសមេដឹកនាំខ្មែរក្រហម ហើយបានសំនូមពរអោយមានការចាក់ផ្សាយពីដំណើរកាត់ទោសនោះទៅដល់ភូមិរបស់ពួកគាត់ផងដែរ។

# ការសិក្សាពីជីវភាពរស់នៅរបស់ប្រជាជននៅបឹងជើងឯក



**បឹងជើងឯក**ជាបឹងធំមួយ ដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញចំងាយ ៥គីឡូម៉ែត្រ។ បឹងនេះបានតភ្ជាប់ជាមួយបឹងប្រាំមួយផ្សេងទៀតគឺ បឹងកក់ បឹងសំពោ បឹងចង់ស្ដី បឹងផ្ទោល និងបឹងសាឡាង។ នៅរដូវប្រាំង បឹងនេះមានក្រឡាផ្ទៃ ១ ៦០០ ហិចតា រីឯនៅរដូវវស្សាមានប្រមាណ ១៣ ០០០ហិចតា។ យោងទៅតាមរបាយការណ៍របស់សាលាក្រុងភ្នំពេញស្ដីពីយុទ្ធសាស្រ្តអភិវឌ្ឍន៏ទីក្រុង បានចាត់ទុកបឹងជើងឯកជាតំបន់មួយសំរាប់ស្តុកទឹកសំណល់ចេញពីទីក្រុងភ្នំពេញ ដូច្នេះបឹងជើងឯកមានសារៈសំខាន់សំរាប់ជាកន្លែងចំរោះទឹក ជាសហគមន៏នេសាទ និងជាកន្លែងដែលប្រជាពលរដ្ឋក្រីក្រនៅទីក្រុងភ្នំពេញបានប្រើប្រាស់ជាមុខរបរចិញ្ចឹមជីវិត។ (នុត លី ២០០៦)



*ការដាំបន្លែនៅលើផ្ទៃបឹងជើងឯករបស់ប្រជាជន*

បឹងជើងឯកមានសារៈប្រយោជន៏ជាច្រើន ជាពិសេសសំរាប់ទ្រទ្រង់ដល់ជីវភាពប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរតំបន់នោះ។ ប៉ុន្តែបច្ចុប្បន្ននេះ *រដ្ឋាភិបាលបានយល់ព្រមជាគោលការណ៍ក្នុងការអភិវឌ្ឍន៏បឹងទំពន់ និងបឹងជើងឯក ដើម្បីឱ្យក្លាយជាទីក្រុងរណបបៃតងមួយ តាមរយៈសារាចរមួយដែលចុះកាលពីថ្ងៃទី ២៤ ឧសភា ២០០៧*។ ហេតុដូច្នេះហើយទើបសិក្ខាកាមជំនាន់ទី២០ នៃសមាគន៏ថែរក្សាបរិស្ថាន និងវប្បធម៌មិនបានធ្វើការសិក្សាជាលក្ខណៈតូចមួយទៅលើប្រធានបទ " ***ជីវភាពរស់នៅរបស់ប្រជាជនបឹងជើងឯក*** " ដើម្បីចងក្រងជាឯកសារដើមមុនពេលដំណើរការគំរោងអភិវឌ្ឍន៏។ ប៉ុន្តែការសិក្សានេះធ្វើឡើងតែក្នុងសង្កាត់ពីរប៉ុណ្ណោះ ដែលមានទីតាំងនៅជាប់នឹងបឹងជើងឯក ហើយប្រជាជននៅទីនោះរស់នៅដោយពឹងផ្អែកច្រើនទៅលើបឹងនោះគឺ សង្កាត់ជើងឯកចំនួន៤ភូមិ និងសង្កាត់ដង្កោ ចំនួន១ភូមិ គឺភូមិខ្វា។ ប្រជាជនសរុបរបស់ភូមិទាំង៥នេះគឺមានចំនួន១៨៥០គ្រួសារ។ ប៉ុន្តែការសិក្សារបស់យើងបានធ្វើការសម្ភាសន៏ផ្ទាល់ជាមួយប្រជាជនតែ ចំនួន១៨៧គ្រួសារប៉ុននោះ។ ក្នុងចំនោមសំណាកទាំង ១៨៧ មាន ១២០សំណាកគឺជាស្ត្រីត្រូវនឹង៦៤.២%និង៨៧សំណាកជាបុរសត្រូវនឹង ៣៥.៨ %។



សំណាក ដែលបានជួបសម្ភាសន៏ភាគច្រើនជាស្ត្រី ដោយសារពេលក្រុមយើង-ចុះសម្ភាសន៏ជាពេល ដែលប្រជាជនធ្វើការភាគច្រើនបុរសចេញទៅធ្វើការក្រៅផ្ទះច្រើនតែស្ត្រីដែលធ្វើការនៅផ្ទះ។ កញ្ញា អ៊ឹម សុផាណារី ជាសិក្ខាកាមម្នាក់ដែលបានចុះទៅសិក្សានៅតំបន់នោះបានបង្ហាញពីការយល់ឃើញរបស់ខ្លួនយ៉ាងដូច្នេះថា" ឆ្លងតាមរយៈការសង្កេតនិងការធ្វើបទសំភាសន៏ជាមួយប្រជាជនទាំង៥ភូមិដោយផ្ទាល់រួចមក គាត់មានការពឹង-



*សកម្មភាពរបស់ក្រុមបណ្តាញសកម្មជនបរិស្ថាននៅក្នុងកម្មសិក្សា*

ផ្អែកច្រើនទៅផលិតភាពរបស់បឹង។ តួយ៉ាង ប្រភពចំនួលសំខាន់របស់ពួកគាត់បានមកពីការនេសាទត្រី និងការដាំបន្លែលើទឹកដូចជា ត្រកួន កញ្ឆែត ផ្កាត្រកៀតនិង ការធ្វើស្រែជាដើម។ បឹងជើងឯកបានផ្តល់ទិន្នផលត្រី សំរាប់ផ្គត់ផ្គង់ជីវភាពប្រជាជនតាមរយៈការបំពេញតំរូវការប្រចាំថ្ងៃ និងបានលក់ដូរខ្លះ។ ចំនែក ការដាំដំណាំលើបឹង មិនត្រឹមតែផ្តល់ការងារដល់ម្ចាស់ដំណាំប៉ុណ្ណោះទេ វាថែមទាំងផ្តល់ការងារដល់ប្រជាជនក្នុងភូមិតាមរយៈ ការស៊ីឈ្នួលបេះបន្លែទាំងនោះ។ ក្រៅពីនេះ ប្រជាជនក៏នៅមានមុខរបរបន្ទាប់បន្សំដែលមិនពឹងផ្អែកទៅលើបឹងដូចជា ការចិញ្ចឹមសត្វ (ជ្រូក មាន់ ទា គោ ក្របី) ដាំដំណាំហូបផ្លែ(ចេក ល្ហុង) និងរបរមិនមែនកសិកម្មផ្សេងទៀតមានជាអាទិ៍ ការលក់ដូរ កម្មករកាត់ដេរតាមរោងចក្រ រត់ម៉ូតូឌុប កម្មករសំណង់ និងជាងដែកជាដើម។ ប្រជាជននៅក្នុងភូមិដែលចុះទៅសិក្សាមានឱកាសទទួលការងារបានច្រើន និងប្រាក់ចំនូលបន្ថែមដោយអាស្រ័យលើបឹង ។

ចំពោះគំរោងអភិវឌ្ឍន៍វិញ ប្រជាជនភាគច្រើនគាត់បានឆ្លើយថាគាត់បានដឹង តាមរយៈការប្រជុំភូមិ ការនិយាយត១គ្នា ប៉ុន្តែពួកគាត់មិនបានដឹងច្បាស់ថាជាគំរោងអ្វីទេ។ គាត់និយាយថាបើជាគំរោងអភិវឌ្ឍភូមិ ឃុំ ដូចជា គំរោងធ្វើផ្លូវ ដាក់ភ្លើងក្នុងភូមិ វាជាគំរោងដ៏ល្អសំរាប់ពួកគាត់។ ប៉ុន្តែ ក៏មានប្រជាជនខ្លះទៀតគាត់ដឹងថា គំរោងនោះជាគំរោងបង្កើតទីក្រុងរណបនៅបឹងជើងឯកដែរ។ ក្នុងចំណោមអ្នកដែលដឹងនោះ ភាគច្រើនគាត់យល់ថាមិនល្អទេ ព្រោះគំរោងនោះនឹងលុបបឹងដែលជាអាងប្រព្រឹត្តិកម្មធម្មជាតិ និងជាប្រភពចំនូលសំរាប់ប្រជាជនដែលពឹងផ្អែកលើបឹងសំរាប់ចិញ្ចឹមជីវិត។ ក្នុងនោះផងដែរ បើគំរោងនៅតែបង្កើតឡើងមែន នោះនឹងធ្វើអោយប៉ះពាល់ដល់ដីរបស់ពួកគាត់ ហើយពួកគាត់បានសំនូមពរអោយមានសំណងដ៏សមស្របដែលអាចទទួលយកបាន ហើយនិងមានការ យល់ព្រមពីពួកគាត់ផងដែរ"។

# ការបង្កើតក្រុមយុវជននៅខេត្តស្ទឹងត្រែង

*ក្រុមយុវជនដែលផ្តួចផ្តើមដោយបណ្តាញសកម្មជនបរិស្ថាន និងមានការគាំទ្រពីសមាគមន៍ថែរក្សាបរិស្ថាន និង វប្បធម៌ ត្រូវបានបង្កើត ឡើងដោយមានការចូលរួមពីយុវជនដែលរស់ នៅតាមដងទន្លេមេគង្គក្នុងភូមិចំនួនប្រាំគឺ ភូមិកោះព្នៅ ភូមិកោះស្រឡៅ ភូមិកោះខនដិន ភូមិខេ និងភូមិកោះគី។*

ខេត្តស្ទឹងត្រែង គឺជាខេត្តមួយក្នុងចំណោមខេត្តទាំងប្រាំរបស់ប្រទេសកម្ពុជាដែលស្ថិតនៅភាគឦសាន។ ខេត្តនេះសំបូរទៅដោយសម្បត្តិធនធានធម្មជាតិជាច្រើន ដូចជាព្រៃឈើ ទន្លេ បឹង បួរ និងប្រភេទជីវៈចំរុះជាច្រើនប្រភេទ (ខេត្តនេះ ត្រូវបានចាត់ថ្នាក់ជាខេត្តដែលមានតំបន់ដីសើមគ្របដណ្តប់ប្រមាណ៤០គីឡូម៉ែត្រ តាមបណ្តោយដងទន្លេមេគង្គ។ តំបន់ដីសើមនេះស្ថិតនៅក្នុងស្រុកចំនួនពីរ រួមមានស្រុកស្ទឹងត្រែង ឃុំសាមគ្គី និងស្រុកថាឡាបរិវ៉ាត់ ឡើងទៅរហូតភាគខាងជើង និងខាងលិច ដែលរួមមានបីឃុំ ឃុំកោះស្នែង ឃុំអូរស្វាយ និងឃុំព្រះរំកិល)[១]។

ប្រជាជនដែលរស់នៅជុំវិញតំបន់នេះ រស់នៅដោយប្រកបរបរកសិកម្មជាចំបង ដើម្បីចិញ្ចឹមជីវិត ដូចជា ការធ្វើស្រែចំការ នេសាទត្រី ចិញ្ចឹមសត្វ និងដាំបន្លែ។ បន្ថែមពីនេះទៀតការលក់ដូរក៏មានបន្តិចបន្តួចផងដែរ(សូមមើលរបាយការណ៍ស្រាវជ្រាវជំនាន់ទី១៩)[២] ទោះបីជាយ៉ាងណាក៏ដោយ ធនធានទាំងនោះកំពុងប្រឈមនឹងការគំរាមកំហែង ពីគំរោងអភិវឌ្ឍន៍ (ក្រុមហ៊ុនដីសម្បទាន)និងកត្តាជាច្រើនទៀត ទោះបីជាមានកិច្ច ខិតខំប្រឹងប្រែងថែរក្សា និងអភិរក្សពីសំណាក់សហគមន៍(សហគមន៍ព្រៃឈើនិងនេសាទ)នៅតាមមូលដ្ឋានយ៉ាងណាក៏ដោយ។ ព្រៃឈើ ត្រូវក្រុមហ៊ុនវិនិយោគទុន ឯកជនផ្តាច់មុខកាន់កាប់ ដោយហាមប្រជាជនមិនឱ្យចុះដកហូតផល និងអនុផល ព្រៃឈើដូចកាលពីមុនទៀត ដែលមានផលប៉ះពាល់យ៉ាងខ្លាំងក្លាដល់ការរស់នៅរបស់ប្រជាជន។ មួយវិញទៀតបទល្មើសនេសាទនៅតែបន្តមាន ដោយសារភាពទន់ខ្សោយក្នុងការអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋាន។

ក្រុមយុវជន ( ដោយមានការផ្តួចផ្តើមពីបណ្តាញសកម្មជនបរិស្ថាន និងគាំទ្រពីសមាគមន៍ថែរក្សាបរិស្ថាន និងវប្បធម៌ ក្រុមយុវជននៅតាមមូលដ្ឋានត្រូវបានបង្កើឡើង) ដែលរស់នៅក្នុងតំបន់បាននិយាយថាបញ្ហាធនធានធម្មជាតិ ជាពិសេស ធនធានត្រី បាននឹងកំពុងទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្លាំងក្លាពីសំណាក់ជនខិលខូច

---

[១] កម្មវិធីប្រើប្រាស់ឱ្យមាននិរន្តរភាព និងអភិរក្សជីវៈចំរុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ២០០៧: ការប៉ាន់ប្រមាណពីឥទ្ធពលអភិរក្សជីវៈចំរុះនៃតំបន់រាំសារទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង

[២] សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) ២០០៨: របាយការណ៍សិក្សាស្រាវជ្រាវពីតម្រូវការធនធានរបស់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គភាគ ខាងលើ ខេត្តស្ទឹងត្រែង

ជនខិលខូចមួយចំនួនតូច។ ការឆក់ និងគប់គ្រាប់បែក នៅតែបន្តមានមកទល់ពេលបច្ចុប្បន្ននេះ ទោះបីជាមានការចុះបង្ក្រាបពីសហគមន៍នេសាទនៅតាមភូមិយ៉ាងណាក៏ដោយ។





ការជ្រើសរើសក្រុមយុវជននៅខេត្តស្ទឹងត្រែង

នៅពេលសួរថា តើធ្វើដូចម្ដេចទើបអាចកាត់បន្ថយ ឬលប់បំបាត់សកម្មភាពល្មើស ច្បាប់ទាំងអស់នេះ ក្រុមយុវជនទាំងនោះបាននិយាយថា ការចូលរួមរបស់យុវជនក្នុងការងារអភិវឌ្ឍន៍សហគមន៍ មានសារៈសំខាន់ណាស់ ព្រោះយុវជនជាចំណែកមួយនៅក្នុងសង្គម ទាំងការអភិវឌ្ឍន៍ទៅរកផ្លូវត្រូវ និងផ្លូវខុស។ សព្វថ្ងៃនេះ ការយល់ដឹងរបស់យុវជននេតាមមូលដ្ឋានទាក់ទងនឹងចំណេះដឹងទូទៅ ការងារ អភិវឌ្ឍន៍ ។ល។ នៅមានកំរិតនៅឡើយ ដូចនេះ សកម្មភាពល្មើសច្បាប់មួយចំនួនយុវជន គឺជាអ្នកប្រព្រឹត្ត។ ប្រសិនបើយុវជនទាំងនោះ-អាចទទួលបាននូវការផ្ដល់សេវាអប់រំផ្សេងៗ ពួកគេអាចឈប់ប្រព្រឹត្តបទល្មើសទាំងនោះ និងអាចបែរមករួមចំណែកថែរក្សា និងអភិរក្ស ធនធានធម្មជាតិវិញ។

មួយវិញទៀត យុវជនត្រូវលើកទឹកចិត្តឱ្យចូលរួមជាមួយសហគមន៍ដើម្បីកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ។ ធ្វើបែបនេះ មានន័យថា សហគមន៍យើងមានចំនួនមនុស្សច្រើនជាងមុន ជាពិសេសយុវជនដែលជាកត្តានាំទៅរកភាពជាគជ័យក្នុងការងារអភិរក្ស និងម្យ៉ាងទៀត វាអាចជាឱកាសសម្រាប់ពួកគេក្នុងការក្រេបយកចំណេះដឹង និង-ចំណេះធ្វើពីសហគមន៍ និង បណ្ដាអ្នកពាក់ព័ន្ធទាំងឡាយ។ ចំនុចនេះមានន័យថា វាជាដំណើរ ការអភិវឌ្ឍន៍ធនធានមនុស្ស ដែលឈានទៅរកការកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។



លោក វ៉ាន់ វិទ្ធី ជាបណ្ដាញសកម្មជនបរិស្ថានជំនាន់ទី១៩ បានសំដែងនូវការយល់ឃើញបន្ទាប់ពីការចុះទៅសិក្សាពីទស្សនៈរបស់ក្រុមយុវជននៅតាមភូមិចំនួនប្រាំនៅតាមដងទន្លេមេគង្គគឺ ភូមិកោះព្នៅ ភូមិកោះកី ភូមិកោះស្រឡៅ ភូមិកោះខនឌិន និងភូមិកោះស្នែង ថា ក្រុមយុវជននៅក្នុងភូមិទាំងប្រាំនេះ មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការបង្កើតជាក្រុមយុវជនការពារបរិស្ថាន។ ពួកគេបានប្រមូលគ្នីគ្នា ដែលជា-យុវជនដូចគ្នាអោយចូល រួម ហើយសង្ឃឹមថា ពួកគេនឹងមានឱកាស ផ្លាស់ប្ដូរបទពិសោធន៍គ្នាជាមួយក្រុមបណ្ដាញសកម្ម ជនបរិស្ថាននៅទីក្រុងភ្នំពេញ ហើយនឹងបង្កើនចំណេះដឹង និងបទពិសោធន៍បន្ថែមទៀត។

# ការបំបួសដើមឈើជាវិធីមួយសំរាប់ទប់ស្កាត់ការបំផ្លាញព្រៃឈើ



*ព្រះសង្ឃពុទ្ធសាសនាបានបំបួសឈើដោយចងរុំព័ទ្ធជុំវិញដើមឈើនោះ ជាមួយនឹងស្បង់ជីពរ ឬសំពត់ជ្រលក់ពណ៌រមៀត ដើម្បីជាសញ្ញាប្រាប់ នូវភាពពិសិដ្ឋរបស់ដើមឈើនោះ។ ប្រសិនបើដើមឈើត្រូវគេរុំព័ទ្ធដោយស្បង់ ឬសំពត់សាដកទៅហើយ គ្មានបុគ្គលណាម្នាក់អាចហ៊ានកាត់ ឬកាប់ផ្ដួលរំលំឡើយ។*

តាមធម្មតា ពិធីបុណ្យបំបួលដើមឈើត្រូវគេចាត់ចែងឡើងសំរាប់តែកុលបុត្រទុកជាទំនៀមទម្លាប់មួយ ដែលជាសញ្ញាបង្ហាញប្រាប់ពីការចូលទៅក្នុងភេទជាបព្វជិតរបស់កុលបុត្រទាំងនោះ។ នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ពិធីបុណ្យបំបួសត្រូវបានគេសម្របសម្រួលសំរាប់បំបួសដើមឈើដែរ។ នៅឆ្នាំ ១៩៩៨ ព្រះសង្ឃដែលបានធ្វើធម្មយាត្រាទៅខេត្តរតនៈគីរីក៏បានបំបួសដើមឈើទុកជានិមិត្តរូបផងដែរ។ ព្រះសង្ឃពុទ្ធសាសនាបានបំបួសឈើដោយចងរុំព័ទ្ធជុំវិញដើមឈើនោះ ជាមួយនឹងស្បង់ជីពរ ឬសំពត់ជ្រលក់ពណ៌រមៀត ដើម្បីជាសញ្ញាប្រាប់នូវភាពពិសិដ្ឋរបស់ដើមឈើនោះ។ ព្រះគ្រូចៅអធិការវត្ត **ពោធារាម** នៅប្រទេសថៃភាគខាងជើងត្រូវបានគេប្រគេនកិត្តិយសជា ព្រះសង្ឃទីមួយហើយ ដែលបានយល់ស្របតាមប្រពៃណីបំបួសកុលបុត្រ ឱ្យទៅជាពិធីបំបួសមឈើនេះ។ ព្រះតេជគុណអង្គនោះបានពង្រីកទំនៀមទម្លាប់នេះអោយទៅជាឧបករណ៍សម្រាប់អប់រំមនុស្សទាំងឡាយអំពីសារប្រយោជន៍នៃបរិស្ថានព្រៃឈើ ហើយនិងគ្រោះថ្នាក់នៃការកាប់បំផ្លាញព្រៃឈើ។ ព្រះតេជគុណចៅអធិការអង្គនោះបានពន្យល់យ៉ាងដូច្នេះថា:

"ប្រសិនបើដើមឈើត្រូវគេរុំព័ទ្ធដោយស្បង់ ឬសំពត់សាដកទៅហើយ គ្មានបុគ្គលណាម្នាក់អាចហ៊ានកាត់ ឬកាប់ផ្ដួលរំលំឡើយ។ ដូច្នេះអាត្មាបានត្រិះរិះគិតថា ប្រហែលគំនិតនេះអាចត្រូវគេប្រើប្រាស់ ដើម្បីបន្ទចបង្អាក់ការកាប់ឈើបាន ហើយអាត្មាភាពក៏បានចាប់ផ្ដើមរៀបចំ បង្កើតពិធីបុណ្យបំបួសដើមឈើនេះ នៅក្នុងព្រៃក្បែរៗវត្ត។ អាត្មាភាពបានហៅទំនៀមទំលាប់នេះថា ជាការបំបួសដើមឈើ ដើម្បីអោយទម្ងន់ដើមឈើនោះរឹតតែមានភាពពិសិដ្ឋឡើង។ ពាក្យថា ការបំបួសដើមឈើ ឮទៅហាក់ដូចជាចម្លែកត្រចៀកចំពោះប្រជាពលរដ្ឋថៃ ព្រោះថាការបំបួសនេះធ្វើឡើងចំពោះតែបុរសភេទប៉ុណ្ណោះ។ ការចំលែកនេះបានជួយផ្សព្វផ្សាយដំណឹងនេះ ឱ្យល្បីរន្ទឺខ្ចរខ្ចាយពីមាត់មួយទៅមាត់មួយ ហូរហែររៀងទៅ"។

ព្រះគ្រូចៅអធិការអង្គនោះបានទទួលជោគជ័យក្នុងការទាក់ទាញអារម្មណ៍ ចំពោះការបំផ្លិចបំផ្លាញបរិស្ថាន ដែលបណ្ដាលឡើងពីការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ព្រះអង្គ ហើយរាជរដ្ឋាភិបាលថៃក្នុងឆ្នាំបន្ទាប់ៗមកក៏បានហាមប្រាមមិនអោយកាប់បំផ្លាញព្រៃឈើ ដើម្បីរួមចំនែកចំពោះការខិតខំខ្នះខ្នែងរបស់ព្រះចៅអធិការអង្គនោះ។ ចាប់តាំងពីពេលនាះមកភិក្ខុសង្ឃដ៏ទៃទៀតក៏បានឯកភាពគ្នាយល់ព្រមថា ការបំបួសដើមឈើនេះ

វាជាមធ្យោបាយមួយនៃការថែរក្សាការពារព្រៃឈើ។ ព្រះភិក្ខុសង្ឃទាំងនោះត្រូវបានគេប្រគេនឋានៈជាព្រះសង្ឃអេកូឡូស៊ី ឬព្រះសង្ឃបរិស្ថាន ដោយសារតែកិច្ចការពារបរិស្ថានរបស់ព្រះអង្គ។ពិធីបុណ្យសាសនាដូចជាការបំបួសដើមឈើនេះជាដើមអាចធ្វើជាឧទាហរណ៍គន្លឹះមួយ ដើម្បីបញ្ជាក់អោយឃើញពីភាពចាំបាច់ជាបន្ទាន់ នៃការថែរក្សាធនធានធម្មជាតិ ព្រមទាំងទុកជាមាគ៌ាមួយនៃការប្រៀនប្រដៅអំពីអន្តរសម្ព័ន្ធរវាងព្រះពុទ្ធសាសនា ធម្មជាតិ និងបរិស្ថានទាំងមូល។

***ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ១៩៩៩: សំរែកព្រៃឈើ***

# ការបង្កើត និងការបំផ្លាញស្រទាប់អូសូន

*ក្លរ៉ូភ្លុយអរ៉ូកាបូន បំផ្លាញស្រទាប់អូសូននៅក្នុងមណ្ឌលអាកាសស្ងប់តាមរយៈការបញ្ចេញអាតូមក្លរសេរី ហើយក្លរដើរតួជាកាតាលីករក្នុងការបំផ្លាញស្រទាប់អូសូន។ អាតូមក្លរមួយអាចបំផ្លាញម៉ូលេគុលអូសូនបានចំនួន១០០ ០០០ម៉ូលេគុល ដោយសារតែវាអាចនៅក្នុងបរិយាកាសពី ៤០ ទៅ១០០ឆ្នាំ។*

ការថែរក្សារបាំង រឺស្រទាប់អូសូនពិតជាចាំបាច់ណាស់ ប៉ុន្តែឧស្ម័នពុលដែលបញ្ចេញពីសកម្មភាពមនុស្សកំពុងតែធ្វើអោយវាខូចខាត។ អូសូននៅមណ្ឌលអាកាសស្ងប់កើតឡើងដោយសារកាំរស្មីព្រះអាទិត្យដែលមានថាមពលខ្ពស់ ប៉ះជាមួយម៉ូលេគុលអូសូន ហើយក៏បំបែកម៉ូលេគុលអូសូននោះទៅជាអាតូមអូសូនសេរីពីរ។ បន្ទាប់មកអាតូមសេរីនោះបានទៅចងសម្ព័ន្ធជាមួយម៉ូលេគុលអុកស៊ីសែនបង្កើតបានជាអូសូន ($O_3$)។ ប៉ុន្តែ អូសូនត្រូវបំបែកទៅវិញដោយធម្មជាតិដោយសារប្រតិកម្មពីរគឺ ប្រតិកម្មរវាងអូសូន និងអុកស៊ីសែន បង្កើតបានជាអាតូមអុកស៊ីសែនពីរ និងមួយទៀតគឺប្រតិកម្មរវាងអូសូន និងពន្លឺព្រះអាទិត្យដែលបំបែកអូសូនទៅជាអាតូមអុកស៊ីសែន និងម៉ូលេគុលអុកស៊ីសែន។

ដូច្នេះហើយ បរិមាណអូសូននៅមណ្ឌលអាកាសស្ងប់វាមានសំនឹងដោយសារតែវដ្តប្រតិកម្មនៃការបង្កើត និងការបំផ្លាញវិញដោយធម្មជាតិ។ កំហាប់អូសូននៅអឌ្ឍគោលខាងជើងខ្ពស់បំផុតនៅរដូវក្តៅ ហើយទាបបំផុតនៅរដូវរងារដោយសារការផ្លាស់ប្តូរកាំរស្មីព្រះអាទិត្យតាមរដូវ។ ជាទូទៅផងដែរ កំហាប់អូសូនខ្ពស់បំផុតនៅតំបន់អេក្វាទ័រហើយថយចុះនៅរយៈកំពស់កាន់តែខ្ពស់ដោយសារតែរស្មីព្រះអាទិត្យខ្លាំងជាងនៅតំបន់ដទៃ។ ទោះជាយ៉ាងណាក្តី ការសិក្សានៅពេលថ្មីៗនេះបានអោយដឹងថា វត្តមាននៃសារធាតុគីមីផ្សេងៗនៅមណ្ឌលអាកាសស្ងប់ បានធ្វើអោយអូសូនបាត់ ស្ថេរភាព រឺគ្មានលំនឹង ហើយវាធ្វើអោយគ្មានស្ថេរភាពប្រតិកម្មនៅទីនោះ។

ក្លរ៉ូភ្លុយអរ៉ូកាបូន ($CFC_S$) ជាឧស្ម័នមិនមានប្រតិកម្ម មិនឆេះ និងមិនពុល ហើយវាត្រូវបានគេប្រើយ៉ាងទូលាយនៅទសវត្សឆ្នាំ១៩៨0 នៅក្នុងទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមកំដៅ ក្នុងរោងចក្រអេឡិចត្រូនិច ក្នុងការលាងសំអាតផ្នែកផ្សេងៗនៃកុំព្យូទ័រ...ជាដើម។ ការប្រើប្រាស់ទាំងនោះបានធ្វើអោយមានការបញ្ចេញ $CFC_S$ ចូលទៅក្នុងបរិយាកាស ដែលជាកន្លែងវានៅលាយគ្នាជាមួយឧស្ម័នផ្សេងទៀត ហើយទៅដល់មណ្ឌលអាកាសស្ងប់ជាយថាហេតុ។ Drs. M. Molina និង S.Rowland បានសន្និដ្ឋាននៅក្នុងឆ្នាំ១៩៧៤ថា $CFC_S$ អាចបំផ្លាញស្រទាប់អូសូននៅមណ្ឌលអាកាសស្ងប់តាមរយៈការបញ្ចេញអាតូមក្លរ (Cl ) ដែលធ្វើអោយកើនឡើងកាំរស្មីព្រះអាទិត្យ និងបណ្តាលអោយមានជំងឺមហារីកស្បែក។ អ្នកទាំងពីរបានបញ្ជាក់ថា ទោះបីជា $CFC_S$មានស្ថេរភាពនៅក្នុងមណ្ឌលអាកាសរចល់( វាអាចស្ថិតនៅទីនោះពី៦0 ទៅ១០០ឆ្នាំ) ក៏វាជាអ្នកបន្ថែមកាំរស្មី



អូសូនធ្លុះធ្លាយនៅអឌ្ឍគោលខាងជើង

ព្រះអាទិត្យនៅមណ្ឌលអាកាសស្ងប់ ដែល $CFC_S$ ត្រូវបំបែកហើយបញ្ចេញអាតូមក្លរសេរី។ បន្ទាប់មកអាតូមក្លរសេរីនឹងបំផ្លាញស្រទាប់អូសូន ដើម្បីបង្កើតជាក្លរអុកស៊ីត និង ម៉ូលេគុលអុកស៊ីសែន។ លើសពីនេះទៅទៀត ក្លរអុកស៊ីតពីរម៉ូលេគុលអាចមានប្រតិកម្ម ជាមួយគ្នាបង្កើត បានជាអាតូមក្លរជាច្រើន និងម៉ូលេគុលអុកស៊ីសែន។ ដូច្នេះ ក្លរដើរតួជាកាតាលីករក្នុងការបំផ្លាញស្រទាប់អូសូន។អាតូមក្លរមួយអាចបំផ្លាញម៉ូលេគុលអូសូនបានចំនួន ១០០ ០០០ម៉ូលេគុល ដោយសារតែវាអាចនៅក្នុងបរិយាកាសពី ៤០ ទៅ១០០ឆ្នាំ។ ដូច្នេះ $CFC_S$ ត្រូវបានគេចាត់ទុកជាអ្នកបំផ្លាញដោយសារវាដើរតួជាអ្នកដឹកជញ្ជូន ដែលបន្តផ្លាស់ទីក្លរចូលទៅក្នុងបរិយាកាស។ ការបំផ្លាញនេះស្ថិតនៅយូរអង្វែងដោយសារតែការបំបាត់ក្លរចេញពីបរិយាកាសមានដំនើរយឺតបំផុត។

ទស្សនៈយុវជន

## ការរក្សាបរិស្ថានតាមទីសាធារណៈក្នុងទីក្រុងភ្នំពេញ

រាជធានីភ្នំពេញ ជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះបញ្ហាអនាម័យទីក្រុងជាកត្តាមួយដែលត្រូវតែយកចិត្តទុកដាក់បំផុត តាមទីផ្សារ តាមផ្លូវសាធារណៈ និង-តាមសួនច្បារនានា ក្នុងរាធានីភ្នំពេញ។ ប៉ុន្តែសព្វថ្ងៃនេះ នៅក្នុងរាជធានីភ្នំពេញមានកន្លែងខ្លះមានបរិស្ថាន និងសណ្តាប់ធ្នាប់ល្អ ប៉ុន្តែកន្លែងខ្លះទៀតមិនទាន់មានសណ្តាប់ធ្នាប់ល្អនៅឡើយទេ។ ទាំងនេះ គឺដោយសារតែអំពើអសុជីវធម៌របស់បុគ្គលអាត្មានិយមមួយចំនួនដែលមិនចូលរួមថែរក្សាបរិស្ថានក្នុងទីក្រុង។ ជាមួយគ្នានេះដែរក៏មានទស្សនៈនិងការព្រួយបារម្ភពីសំណាកនិស្សិតដែលកំពុងតែសិក្សាតាមគ្រឹស្ថានអប់រំនានា ក្នុងរាជធានីភ្នំពេញជុំវិញអនាម័យទីក្រុងផងដែរ។

កញ្ញា ខៀវ ពេជ្រម៉ូនាថ អាយុ ១៩ឆ្នាំ ជានិស្សិតឆ្នាំទី២ នៃសាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រ ផ្នែកគិលានុបដ្ឋាយិកា បានបង្ហាញអំពីការព្រួយបារម្ភរបស់ខ្លួនផងដែរថា "សព្វថ្ងៃនេះ មានប្រជាជនយើងជាច្រើនដែលបានទៅកំសាន្តតាមសួនច្បារនានាក្នុងរាជធានីភ្នំពេញជារៀងរាល់ថ្ងៃ ជាពិសេសនៅល្ងាចថ្ងៃសៅរ៍ និងអាទិត្យ តែពួកគេបែរជានាំគ្នាបោះចោលសំរាមនៅទីនោះទៅវិញ។ ម្យ៉ាងទៀត បើនៅតាមផ្លូវសាធារណៈវិញក៏មានបុគ្គលមួយចំនួនតែងតែទៅបន្ទោរបង់ផ្តេសផ្តាស ដែលអាចបង្ករអោយប៉ះពាល់ដល់សុខភាពមនុស្ស និងជាអំពើអសីលធម៌មួយផងដែរ។"



ចំនែកឯលោក ង៉ែត សុភី អាយុ ២៤ឆ្នាំ ដែលជានិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ផ្នែកសេដ្ឋកិច្ចកសិកម្ម និងភិវឌ្ឍន៍ជនបទក៏មានការព្រួយបារម្ភពីបញ្ហានេះដែរ។ លោកក៏មានការយល់ឃើញស្រដៀងគ្នាដែរថា ប្រជាជនភាគច្រើនពុំមានឥរិយាបថត្រឹមត្រូវក្នុងការចោលសំរាម អោយមានលក្ខណៈសមស្របទៅតាមក្បួនខ្នាតនៅឡើយទេ គឺថាពួកគាត់មានអនាម័យផ្ទាល់ខ្លួនក្នុងការរស់នៅក្នុងគ្រួសារ ក៏ប៉ុន្តែពួកគេពុំបានយកទុកចិត្តដាក់ជាមួយនឹងអនាម័យរួមនៅក្នុងទីក្រុងឡើយ។ ជាឧទាហរណ៍ ប្រជាជនមានការប្រមូលសំរាមបានល្អនិងវេចខ្ចប់យ៉ាងត្រឹមត្រូវនៅក្នុងផ្ទះរបស់គាត់រៀងខ្លួន ប៉ុន្តែពេលគាត់យកសំរាមទៅចោល ពួកគាត់ពុំបានគិតថាសំរាមដែលពួកគាត់ចោលមានការវិចខ្ចប់សមស្រប ឬអត់

នោះឡើយ គឺចោលអោយតែរួចពីដៃ បណ្តាលអោយមានភាពរប៉ាត់រប៉ាយ និងជះក្លិនស្អុយមកខាងក្រៅធ្វើអាយបាត់បង់សោភ័ណភាពទីក្រុង។

ជុំវិញបញ្ហាទាំងនេះ ពួកគេទាំងពីរនាក់ ក៏មានទស្សនៈដូចគ្នាដែរថា ប្រជាជនទាំងអស់ ពិសេសយុវជនត្រូវតែរួបរួមគ្នា ក្នុងការថែរក្សាអនាម័យទីក្រុងរបស់យើងទាំងអស់គ្នា តាមរយៈឥរិយាបថនៃការរស់នៅស្អាតក្នុងសង្គមគ្រួសារក៏ដូចជានៅតាមទីសាធារណៈ និងត្រូវមានសីលធម៌ក្នុងការរស់នៅផងដែរ ដូចជា ការមិនបន្ទោរបង់ពាសវាលពាសកាលគ្មានសណ្តាប់ធ្នាប់ជាដើម។

***ដោយកញ្ញា សេង សុរចនា បណ្តាញសកម្មជនបរិស្ថាន***

***ជំនាន់ទី ១៩***

# ពីនេះ ពីនោះ ពីបរិស្ថាន

## ឈើប្រើប្រាស់ជាប្រភពថាមពល

នៅលើពិភពលោកមានប្រជាជនជាង២៣០០លាននាក់ ដែលរស់នៅពឹងផ្អែកលើ Biomass សំរាប់ការប្រើប្រាស់ក្នុងការចំអិនអាហារ និងដុតកំដៅ ហើយក៏មានមនុស្សជាច្រើនលាននាក់រកចំនូលបានពីការលក់ឈើសំរាប់ការប្រើប្រាស់ជាងប្រភពថាមពល និងអុសធ្យូង។ តាមការប៉ាន់ស្មានទៅប្រទេសកម្ពុជាមានឈើមិនមែនឈើហ៊ុប(ចំនួន៦លានម៣/ឆ្នាំ) ត្រូវបានគេយកមកប្រើប្រាស់ជាប្រភពឥន្ធនះ(អុស និងធ្យូង) ដុតចំអិនអាហារ និងសំរាប់ឡឧស្សាហកម្ម (ឧទាហរណ៏ះ ឡឥដ្ឋ ក្បឿង ឡចំហុយ សន្លឹកថ្នាំជក់ ឡរំងាស់ស្ករ ត្នោត ឡចំហុយស្បៀងជាដើម) ។ល។

**(ទស្សនាវដ្តី កសិកម្ម ២០០៦)**

## សារៈសំខាន់នៃជលផលទឹកសាប

ជលផលទឹកសាបកម្ពុជា មានផលិតភាពខ្ពស់ជាងគេក្នុងពិភពលោក( ១៣.៩- ២៣តោន/គ.ម២) ដោយសារប្រពន្ធ័ទន្លេមេគ្គ និងស្ទឹងនានាដ៏សំបូរបែប រួមដោយនាទីព្រៃលិចទឹកនៅតាមដងទន្លេមេគង្គ និងបឹងទន្លេសាបផងដែរ។ ផលនេសាទទឹកសាបកម្ពុជា ស្ថិតក្នុងលំដាប់លេខរៀងទី៤ ក្នុងពិភពលោកបន្ទាប់ពីចិន ឥណ្ឌា និងបង់ក្លាដែស ប៉ុន្តែបើគណនាការទទួលបាននៃប្រជាជនម្នាក់ៗវិញ កម្ពុជាទទួលបានចំនាត់ថ្នាក់ទីមួយដែលមានបរិមាណរហូតដល់ទៅ ២០.០៩គ.ក្រ ចំនែកឯចិនបានត្រឹមតែ ០.៩៧គ.ក្រ ឥណ្ឌាបាន០.៤១គ.ក្រ និងបង់ក្លាដែស ៤.៥៨គ.ក្រ ប៉ុណ្ណោះក្នុងមួយឆ្នាំ។

**(ទស្សនាវដ្តី កសិកម្ម ២០០៦)**

## សំណង់ និងតួនាទីនៃទំនប់

ជិត១៥ភាគរយនៃការផ្គត់ផ្គង់ទឹកប្រចាំឆ្នាំនៅលើពិភពលោក អាចត្រូវបានស្តុកទុកនៅក្នុងអាងស្តុកទឹកចំនួន ២៨ ០០០អាងនៅលើពិភពលោក។ ផលចំណេញនៃទំនប់ និងអាងស្តុកទឹកគឺ ការចែកចាយថាមពលអគ្គីសនី និងផ្គត់ផ្គង់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រ ការពារស្បៀងអាហារ ផ្តល់ទឹកប្រើប្រាស់ក្នុងគ្រួសារ និងឧស្សាហ៏កម្ម។ ដីកសិកម្មច្រើនជាង ៥០ភាគរយក្នុងប្រទេសចំនួន៧ស្រោចស្រពដោយទឹកដែលបានមកពីទំនប់។ ប៉ុន្តែ ដោយសារការផ្លាស់ប្តូរយ៉ាងខ្លាំងនៃលំហូរទឹកទន្លេទៅក្នុងបឹងបួរ ទំនប់ និងអាងស្តុកធំៗ បង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន។ ការបាត់បង់ចំហាយទឹក បំភាយមេតាន ឬអ៊ីដ្រូសែនស៊ុលភីត និងបង្កើនគ្រោះថ្នាក់ដល់សុខភាពដោយសារតែការផ្តល់ជំរកដល់ពពួកចំលងរោគ។ ផលប៉ះពាល់ចំបងនោះគឺ អាងទឹកនៃខ្សែទឹកខាងក្រោម និងខាងលើត្រូវគរដោយគំនរល្បាប់ និងការបែងចែកទន្លេដោយសង់ទំនប់កាត់។ អាងទឹកធំៗបានកាត់បន្ថយសម្តភាពផ្ទុកគំនរល្បាប់នៅលើពិភពលោកចំនួន២០ភាគរយ និងធ្វើឱ្យមានការហូរច្រោះនៅក្នុងខ្សែទឹកទន្លេ និងបរិស្ថានតាមច្រាំងទន្លេ។ ការសង់ទំនប់កាត់ទន្លេ មានឥទ្ធិពលទៅលើជំរកនៅតាមច្រាំទន្លេ និងជាឧបសគ្គដល់ការផ្លាស់ទីរបស់សត្វក្នុងទឹក។ ៥២ភាគរយនៃអាងទន្លេធំៗនៅលើពិភពលោកត្រូវគេធ្វើទំនប់កាត់។

***(GLOBAL CHANGE: Enough Water for All?, 2007)***

## តំបន់ជីវៈចំរុះប្រទេសកម្ពុជា

យោងតាមលក្ខណៈស្ថានប្រព័ន្ធ ប្រទេសកម្ពុជាត្រូវបានបែងចែកជាតំបន់ជីវៈចំរុះចំនួន៧គឺ បណ្តោយឆ្នេរសមុទ្រ និងទឹកសមុទ្រប៉ែកនិរតី ទំនាបប៉ែកខាងជើង តំបន់ព្រៃឈើភាគឥសា-ណ្យខេត្តកំពង់ចាម តំបន់ដីសណ្តទន្លេមេគង្គ ព្រៃលិចទឹកបឹងទន្លេសាប និងតំបន់ភាគពាយ័ព្យនៃប្រទេស។ ក្នុង-ចំណោមតំបន់ទាំងអស់ តំបន់បណ្តោយឆ្នេរសមុទ្រ និងទឹកសមុទ្រប៉ែកនិរតី ទំនាបភាគខាងជើង និងព្រលិចទឹកបឹងទន្លេសាបត្រូវបានគេចាត់ទុកជាតំបន់ ដែល-មានអាទិភាពខ្ពស់ក្នុងការអភិរក្សជាងតំបន់ក៏ទៃទៀត។

## វេទិការ សំណួរ និងចំលើយ



**១. តើមួយណាដែលមិនមែនជាឥន្ធនៈផូស៊ីល?**

ក.ប្រេង

ខ.ឧស្ម័ន

គ. អ៊ុយរ៉ាញ៉ូម

ឃ. ធ្យូងថ្ម

**២. តើចំលើយណាមួយក្នុងចំនោមចំលើយខាងក្រោមនេះដែលជាមូលហេតុចំបងដែលនាំឱ្យមាននគរូបនីយកម្ម**

ក. ប្រជាជនបំលាស់ទីចេញពីកណ្ដាលទីក្រុង

ខ.ប្រជាជនផ្លាស់ទីពីតំបន់ជនបទទៅកាន់ទីក្រុង

គ. ប្រជាជនផ្លាស់ទីចេញពីទីប្រជុំជនទីក្រុង និងប្រជាជនផ្លាស់ទីពីទីជនបទមកកាន់ទីក្រុង

ឃ. ការសំរេចចិត្តរបស់រាជរដ្ឋាភិបាលដើម្បីផ្លាស់ទីប្រជាជនទាំងអស់ទៅកាន់តំបន់ទីក្រុង

**៣. តើការយកពន្ធលើប្រភេទថាមពលដែលមិនកកើតឡើងវិញអាចទទួលបានជោគជ័យអ្វីខ្លះ?**

ក.កាត់បន្ថយការបំពុល ហើយបង្កើននូវការប្រើប្រាស់ធនធានកកើតឡើងវិញ

ខ.តំឡើងនូវតំលៃថាមពលគ្រប់ប្រភេទ

គ. បង្ខំឱ្យឧស្សាហកម្មឈប់ដំនើរការ

ឃ. ដោះស្រាយនូវរាល់បញ្ហាបរិស្ថានទាំងអស់

**៤. តើការយកពន្ធលើប្រភេទថាមពលដែលមិនកកើតឡើងវិញអាចទទួលបានជោគជ័យអ្វីខ្លះ?**

ក.កាត់បន្ថយការបំពុល ហើយបង្កើននូវការប្រើប្រាស់ធនធានកកើតឡើងវិញ

ខ.តំឡើងនូវតំលៃថាមពលគ្រប់ប្រភេទ

គ. បង្ខំឱ្យឧស្សាហកម្មឈប់ដំនើរការ

ឃ. ដោះស្រាយនូវរាល់បញ្ហាបរិស្ថានទាំងអស់

**ចំលើយ:** ១.គ ២.គ ៣.ក ៤.ក

## កំណាព្យ  សំរស់ធម្មជាតិនាដងទន្លេខេត្តស្ទឹងត្រែង(បទពាក្យ៧)

១. ស្ទឹងត្រែងសំបូរដោយធម្មជាតិ  
គឺជាមរតកពីដូនតា  
ស្រស់ល្អព្រោងព្រាតគួរចេតនា  
ជាទីទស្សនារបស់មនុស្សលោក ។

២. មានទន្លេធំចំនួនបួន  
សេសានសេកុងបានឈរឈ្មោះ  
បើតាមច្បាប់ក្បួនបានចានោះ  
ស្រែពករួមរស់នឹងមេគង្គ ។

៣. មានតាំងពីសត្វ និងព្រឹក្សា  
ជាទីកំនើតទីសុខុដុម  
គង្គា មច្ឆាតពូជពង្ស  
ជាទីប្រជុំសត្វទាំងឡាយ ។

៤. បើសិនជាយើងធ្វើដំណើរ  
ពពួកបក្សីទាំងហ្វូងហ្វាយ  
នោះយើងអាចមើលលំហែកាយ  
ហោះហើររាយប៉ាយពេញវេហា ។

៥. ចំនែកនៅតាមដងទន្លេ  
ថ្នាំជក់ ឪឡឹក ពោតសព្វសារ  
សងខាងដីទេរមានចំការ  
មានទាំងផល្លានុផលព្រៃ ។

៦. ក្នុងទឹកក៏មានធនធានដែរ  
មានសត្វតូចៗ ពួកសិប្បី  
មានពពួកស្លែមានទាំងត្រី  
រស់ដោយសេរីគ្មានរំខាន ។

៧.ព្រំដែនខ្មែរ-ឡាវមានសត្វមួយ  
នោះគឺត្រីផ្សោតដែលយើងបាន  
ឈ្មោះវារញ្ជួយពេញអស់ឋាន  
អភិរក្សសុខសាន្តនៅបិតបេរ ។

១០. ផ្ទៃទឹកទន្លេថ្លាល្អះ  
ពន្លឺព្រិចៗគួរគ្មាន់គ្មេរ  
មិនដែលប្រទះពីមុនទេ  
នៅពេលសូរិយេទន់ទាបទៅ ។

១១. កោះខ្សាច់តូចធំប្រៀបដូចជ្រោយ  
ទាំងសត្វ ទាំងមនុស្សតែងសំដៅ  
ពទ្ធ័ជុំវិញដោយទឹករាក់ជ្រៅ  
សំចតឈប់នៅមួយគ្រាសិន ។

១២. ធម្មជាតិស្ទឹងត្រែងល្អប្រណិត  
ដូច្នេះត្រូវរៀនពីបំនិន  
ទិដ្ឋភាពពិតៗមិនសុបិន  
ហើយយើងនឹងមិនបំផ្លាញវា ។

***រៀបរៀង និង និពន្ធដោយៈ កញ្ញា គី ណាខ្សែន***  
***និង កញ្ញា រិន សុផាត***

## ដំណឹងសិក្សា

គម្រោងបណ្តុះបណ្តាលសកម្មជនបរិស្ថាននៃអង្គការសេប៉ា មានបើកវគ្គបណ្តុះបណ្តាលចំនួនពីរដងក្នុងមួយឆ្នាំ ដោយលើកទីមួយនៅក្នុងខែមិថុនា និងលើកទីពីរនៅក្នុងខែធ្នូ ។ ចំពោះអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនងមកកាន់ការិយាល័យអង្គការសេប៉ា ។

## ជូនចំពោះមិត្តអ្នកអាន

សូមប្រិយមិត្តអ្នកអានទាំងអស់ មេត្តាជួយផ្តល់នូវការិះគន់ក្នុងន័យស្ថាបនា ដល់ព្រឹត្តិប័ត្រ "យុវជន និងបរិស្ថាន" របស់យើងខ្ញុំ និងផ្តល់នូវព័ត៌មានផ្សេងៗ ស្តីពីបញ្ហាបរិស្ថាននៅតំបន់របស់លោកអ្នក មកកាន់បណ្តាញសកម្មជនបរិស្ថានយើងខ្ញុំ តាមរយៈទូរស័ព្ទលេខ (៨៥៥)២៣ ៣៦៩ ១៧៩/៨៨១ ៦១៣ ឬអ៊ីម៉ែល newsye@citylink.com.kh ដើម្បីចូលរួមការពារបរិស្ថានយើង ។ យើងខ្ញុំមានក្តីសង្ឃឹម និងសូម អរគុណដល់ការសហការរបស់លោកអ្នក ។ សូមអរគុណ !!!

## កំសាន្ត និង សំណើច

ជួយពិចារណាផង.... !..?

## វេទិកាចែកជើង (តចប់)

**សត្វខ្យង:** ខ្ញុំមកនេះមិនមែនមកប្រលងយកចាញ់ឈ្នះជាមួយបងសុភាទន្សាយទេ តែចង់ឱ្យបងជួយរកដំណោះស្រាយវិញ គឺថាអំបូររបស់ខ្ញុំវិញក៏មិនអន់ដែរខាងរឿងបង្កើតកូនចៅ តែនៅមិនអាចបំពេញតាមតំរូវការរបស់មនុស្សបានទៀត។ កាលពីមុនគេរាប់ខ្ញុំជាផ្លូន១ ចំណែកឥឡូវវិញគេចាប់ខ្ញុំថ្លឹង និងដណ្ដើមគ្នាទិញដោយប្រញាប់។ ម្ដេចអញ្ចឹងបងសុភា ?

**សុភាទន្សាយ:** មកពីមនុស្សខ្វះធនធានទិញសាច់ដូចជា: បងគោ មាន់ ទា ទើបមានការប្រញាប់ទិញបែបនេះ។ រិតតែអាណិតដល់មនុស្សទាំងនោះមួយក៏រិតថែមទៀតហើយ!!

**កណ្ដុរ:** រូបនាងខ្ញុំក្ដៅក្រហាយណាស់បងសុភា ខ្សែស្រឡាយខ្ញុំស្ទើរតែផុតពូជពីស្រុកទេសហើយ ពីមួយឆ្នាំទៅមួយឆ្នាំជីវិតពួកខ្ញុំត្រូវស្លាប់ដោយសារការប្រមាថពីមនុស្សរាប់លានក្បាល។ ឥឡូវនេះ សាច់ពួកខ្ញុំកំពុងមានប្រជាប្រិយភាព ចរាចរយ៉ាងគគ្រឹកគគ្រេង និងពេញនិយមបំផុតនៅស្រុកស្រែចំការ។ ដោយឃើញសភាពបែបនេះ ម្ដាយមួយចំនួនអស់កំលាំងកាយចិត្ត ក្នុងការបង្កើតកូនចៅ ព្រោះដូចជាមិនធូរធារសោះ។ តើមានដំណោះស្រាយណាខ្លះសំរាប់ពួកខ្ញុំ ?

**សុភាទន្សាយ:** ខ្ញុំសូមមិនឆ្លើយតបដោយហេតុតែវាប្រហាក់ប្រហែលនឹងចំលើយរបស់បងឆ្កែ និងបងខ្យងដែរ។ តែសូមផ្ដាំដល់មាតាទាំងអស់សូមកុំបាក់ទឹកចិត្តអី គឺទ្រាំទៅក្រែងលោថ្នាក់លើគេកែទម្រង់។

សុភាទន្សាយបាននិយាយបន្ថែមដើម្បីលើកទឹកចិត្តសត្វទាំងអស់ថា: សូមបងប្អូនកុំបារម្ភណ៍អ្វី ព្រោះខាងរាជរដ្ឋាភិបាលបានចេញច្បាប់យ៉ាងតឹងរឹងចំពោះការអភិរក្សសត្វព្រៃហើយ។ ម្យ៉ាងទៀត កាលណាពួកសត្វយើងផុតពូជអស់ទៅមនុស្សក៏លែងសំលាប់ និងធ្វើបាបយើងទៀតដែរ។

និយាយដល់ត្រឹមនេះ ស្រាប់តែលឺសូរស្នូរជើងមនុស្សដើរមក សុភាទន្សាយភ័យណាស់ក៏ប្រកាសរំសាយវេទិកាកណ្ដាលទី ហើយពពួកសត្វទាំងអស់ក៏នាំគ្នារត់ចែកជើងគ្នា ទៅលំនៅរៀងខ្លួនដោយភ័យខ្លាច។

## ១ ម៉ឺន ឆ្លងនឹង ១រយ

មានតំណាលដូចតទៅ:

មានបុរសម្នាក់មានចំនេះវិជ្ជាជ្រៅជ្រះអាចដោះប្រស្នា និងពាក្យបណ្ដៅផ្សេង១បាន។ ថ្ងៃមួយ បុរសនេះបានជួបនឹងក្មេងគង្វាលគោម្នាក់ ហើយបាននិយាយប្រាប់ក្មេងគង្វាលនោះនូវចំនេះវិជ្ជារបស់ខ្លួន អួតប្រាប់គ្នាទៅវិញទៅមក:

**បុរសមានចំនេះវិជ្ជា:** នែ៎ ! ក្មេងឃ្វាលគោ ឯងឃ្វាលគោតែ អីចឹង ឯងប្រាកដជាគ្មានចំនេះវិជ្ជាទេណា? យល់ល្អ ឯងចូលសាលារៀនទៅទើបមានចំនេះដឹង មានចំនេះវិជ្ជា ដូចជាយើង។

**ក្មេងគង្វាលគោ:** ថ្វីត្បិតតែយើងជាក្មេងឃ្វាលគោមែន! តែយើងនេះមានពាក្យបណ្ដៅមួយដែលអ្នកដ៏ទៃមិនអាចដោះស្រាយបាន បើឯងជាអ្នកមានចំនេះដឹងមែន តើឯងអាចដោះស្រាយរកឃើញទេ?

**បុរសមានចំនេះវិជ្ជា:** យើងប្រាកដជាឆ្លើយរួច តើសំនួរអ្វីទៅ ?

**ក្មេងគង្វាលគោ:** បើសិនជាឯងឆ្លើយមិនរួចវិញ តើឯងហ៊ានភ្នាល់ដាក់អី?

**បុរសមានចំនេះវិជ្ជា:** បើសិនជាឆ្លើយមិនរួចទេ យើងឱ្យឯង១ម៉ឺន ប៉ុន្តែបើយើងឆ្លើយរួចវិញ យើងយកពីឯងតែ១រយរៀលតែប៉ុណ្ណោះ។

**ក្មេចគង្វាលគោ:** ល្អ ! អញ្ចឹងតើសត្វអ្វីមានជើងពីរ ក្បាលមួយ ភ្នែកពីរលាន? ឆ្លើយមក,,,,,,

**បុរសមានចំនេះវិជ្ជា:** សត្វអីហ្នឹង?( កំពុងគិតក្នុងចិត្ត ) ឥឡូវយើងឆ្លើយមិនរួចទេ យក១ម៉ឺនទៅ។ ប៉ុន្តែយើងសួរឯងវិញ តើនោះជាសត្វអ្វី? ឆ្លើយមក,,,,,

**ក្មេងគង្វាលគោ:** ចំនែកយើងក៏ឆ្លើយមិនរួចដែរ យក ១ រយទៅ។